# ការណែនាំអំពីការស្វែងរកកូដ HS

**កូដសម្រាប់សម្គាល់ប្រភេទទំនិញ (HS Code)** គឺមានសារៈសំខាន់សម្រាប់ការបញ្ជូនទំនិញនាំចូលទៅកាន់ប្រទេស/តំបន់ផ្សេងៗ។ វាអាចមានឈ្មោះផ្សេងៗទៅតាមទីតាំងនៃការដឹកជញ្ជូន ដូចជា **កូដកំណត់ប្រភេទពន្ធ** (HTS) សម្រាប់សហរដ្ឋអាមេរិក។
ដើម្បីដឹកជញ្ជូនទៅកាន់សហរដ្ឋអាមេរិក ការបញ្ចូលកូដ HTS 10 ខ្ទង់ត្រឹមត្រូវ ជួយកំណត់ និងចាត់ថ្នាក់ទំនិញនាំចូល ដើម្បីជៀសវាងការពន្យារពេលការបញ្ជូនទំនិញ ការចំណាយបន្ថែម និងការឃាំងទំនិញទុក។
FedEx ផ្ដល់ជូនឧបករណ៍ដូចខាងក្រោម ដើម្បីជួយអតិថិជនស្វែងរកកូដ HS ត្រឹមត្រូវ សមស្របតាមវិធីសាស្ត្រដឹកជញ្ជូន និងចំណង់ចំណូលចិត្តផ្សេងៗ៖

| ឧបករណ៍ | ការពិពណ៌នា | សមស្របសម្រាប់ |
|---|---|---|
| Global Trade Manager (GTM) | ឧបករណ៍អនឡាញនេះអាចជួយលោកអ្នកកំណត់កូដ HS ត្រឹមត្រូវសម្រាប់ផលិតផលរបស់លោកអ្នក។ លោកអ្នកអាចចូលប្រើវាតាមគេហទំព័រ FedEx ហើយប្រើវាដើម្បីស្វែងរកកូដដោយប្រើការពិពណ៌នាផលិតផល។ | អតិថិជនទូទៅដែលត្រូវការវិធីសាមញ្ញក្នុងការស្វែងរកកូដ HS។ |
| FedEx Ship Manager™ at fedex.com (FSM) | ជាផ្នែកមួយនៃ FSM នៅលើ fedex.com លោកអ្នកអាចស្វែងរកកូដ HS តាមពាក្យគន្លឹះពាក់ព័ន្ធនៅពេលបង្កើតការដឹកជញ្ជូន។ | អតិថិជនដែលប្រើ FSM នៅលើ fedex.com ដើម្បីបង្កើតការដឹកជញ្ជូន។ |
| HS code lookup API | HS Code Lookup API នេះអនុញ្ញាតឱ្យបញ្ចូលមុខងារស្វែងរកកូដ HS ដោយផ្ទាល់ក្នុងប្រព័ន្ធ ឬគេហទំព័រ eCommerce របស់លោកអ្នក។ | អតិថិជនដែលប្រើ FedEx API ដើម្បីភ្ជាប់ដោយផ្ទាល់ជាមួយ FedEx។ |

| | | |
|---|---|---|
| | វាសមស្របសម្រាប់អាជីវកម្មដែលមានតម្រូវការបច្ចេកទេសពិសេស។ | |

**ចំណាំ៖** ទាមទារការចូលប្រើគណនី fedex.com ដើម្បីប្រើប្រាស់ឧបករណ៍ទាំងអស់ខាងលើ។

| **ឧបករណ៍ឌីជីថលរបស់** FedEx | **ជំហានងាយៗដែលត្រូវអនុវត្ត** |
|---|---|
| Global Trade Manager (GTM) | 1. ចូលទៅកាន់ Global Trade Manager៖ https://www.fedex.com/GTM?cntry_code=kh<br>2. ចុចលើ "Harmonized Code Search" បន្ទាប់មក ចូលគណនីរបស់លោកអ្នក។<br><br><br>3. ជ្រើសប្រទេស/តំបន់គោលដៅ ហើយបញ្ចូលការពិពណ៌នាផលិតផល ឬកូដ HS ដែលអ្នកចង់ស្វែងរក។<br><br><br>4. ស្វែងរកការពិពណ៌នានិងកូដ HS ដែលសមស្របបំផុតនឹងទំនិញដែលលោកអ្នកចង់ចាត់ថ្នាក់។ |




FedEx Ship Manager™ នៅលើ fedex.com (ទិដ្ឋភាពបង្រួម/ទិដ្ឋភាពងាយស្រួលមើល)

**របៀបស្វែងរកកូដ HS នៅលើ FSM៖**

1. ចុច “បញ្ចូនវត្ថុថ្មី” ដើម្បីបន្ថែមទំនិញក្នុងផ្នែក “ខ្លឹមសារកញ្ចប់ទំនិញ”។




2. បញ្ចូលពាក្យគន្លឹះពាក់ព័ន្ធ ដើម្បីស្វែងរកកូដ HS នៅក្នុងកន្លែង “កូដសម្រាប់បញ្ជាក់ប្រភេទទំនិញ”។

<table>
<tr><td></td><td>

<br>
3. ស្វែងរកការពិពណ៌នានិងកូដ HS ដែលសមស្របបំផុតនឹងទំនិញដែលអ្នកចង់ចាត់ថ្នាក់។ បំពេញព័ត៌មានទំនិញផ្សេងទៀត ហើយចុច “រក្សាទុក” ដើម្បីបញ្ចប់។</td></tr>
<tr><td>FedEx APIs</td><td>សូមដាក់សំណើសុំប្រើប្រាស់ HS Code Lookup API តាមរយៈ៖ FedEx API Request Form. បន្ទាប់ពីធ្វើការផ្ទៀងផ្ទាត់ FedEx នឹងទំនាក់ទំនងទៅកាន់លោកអ្នក ដើម្បីផ្តល់ការណែនាំលម្អិតអំពីការសរសេរកូដ។<br><br>ចំណាំ៖ HS Code Lookup API មានសម្រាប់អតិថិជនដែលភ្ជាប់ប្រព័ន្ធ FedEx API ដោយផ្ទាល់ដើម្បីដឹកជញ្ជូនជាមួយ FedEx។</td></tr>
</table>